# ៥២- រឿង អាមាត្យរក្សាញៅព្រះរាជទ្រព្យ

មាននិទានមួយដំណាលថា : មានអាមាត្យម្នាក់តែងរក្សានិងរាប់ផ្លែញៅព្រះរាជទ្រព្យ របស់ព្រះមហាក្សត្រមួយអង្គ កាលណាផ្លែញៅនោះទុំ ក៏បេះយកទៅថ្វាយជានិច្ចពុំដែលខាន គាប់ជួនថ្ងៃមួយនោះ បុរសម្នាក់កាន់ទំពក់ទៅបេះផ្លែញៅ ដើរទៅក្បែរខាងដើមញៅ ដែលអាមាត្យនៅចាំរក្សានោះ ។ អាមាត្យមើលទៅ យល់បុរសនោះកាន់ផ្លែញៅនៅថ្នក់ ទំពក់នៅដៃ ក៏ទៅរាប់ផ្លែញៅនៅដើមនោះមើល ឃើញតែទងទទេទើបគិតថា “ សមជាអាលីទំពក់នឹងផ្លែញៅដើរទៅអម្បាញ់មិញ នេះឯង ជាចោរលួច ” ។ អាមាត្យក៏រត់ទៅតាមចៅនោះ ឃើញមានផ្លែញៅនៅថ្នក់ទំពក់នៅដៃមែន ហើយក៏ចាប់កោះយកទៅប្ដឹងចៅក្រមថា “ ចៅនេះឯង ជាចោរលួចផ្លែញៅព្រះរាជទ្រព្យ ខ្ញុំចាប់បានផ្លែញៅនៅថ្នក់ទំពក់នៅដៃ ” ។

ចៅក្រមដណ្ដឹងសួរថា “ ចៅឯងជាចោរលួចបេះផ្លែញៅព្រះរាជទ្រព្យមែនឬទេ ? ” ។ ចៅនោះឆ្លើយថា “ ខ្ញុំមិនមែនជាចោរលួចទេ, ឯផ្លែញៅនេះខ្ញុំបេះមកពីព្រៃដទៃទៀតទេ ” ។ ទើបចៅក្រមនាំសេចក្ដីនោះ ទៅក្រាបបង្គំទូលព្រះមហាក្សត្រតាមដំណើរសេចក្ដីនោះសព្វគ្រប់ ។

ព្រះមហាក្សត្រមានបន្ទូលថា “កុំអាលឲ្យគាបវាឡើយ” ហើយត្រាស់បង្គាប់ឲ្យយកផ្លែញៅអំពីចៅនោះ ទៅដាក់ផ្ទាប់ទល់នឹងទង ដែលផ្លែញៅជ្រុះចេញទៅនោះ តើត្រូវឬមិនត្រូវ រួចសឹមទម្លាក់ផ្លែញៅនោះទៅដី ហើយពិចារណារកដើមហេតុឲ្យឃើញពិតប្រាកដសិនបើឃើញថា គួរមានទោសសឹមធ្វើទោសវា ” ។

អាមាត្យទទួលព្រះរាជឱង្ការ ហើយយកផ្លែញៅនោះទៅដាក់លនឹងទងញៅ ឃើញថាមិនត្រូវទំនងគ្នាសោះ ហើយទម្លាក់ទៅដី ផ្លែញៅនោះក៏ជ្រុះទៅក្នុងថ្លុកកប់ភក់ទៅ ។ ព្រះអង្គឲ្យយកផ្លែញៅ ដែលជ្រុះអំពីមុននោះទៅដាក់ផ្ទាប់លមើល ក៏ឃើញត្រូវនឹងទងនោះមែន ហើយត្រាស់បង្គាប់ឲ្យយកផ្លែញៅខុសនឹងទងវាឲ្យទៅបុរសលីទំពក់វិញ ហើយឲ្យបើកលែងទៅ ។ ចៅនោះក៏យកទំពក់និងផ្លែញៅរបស់ខ្លួនទៅកាន់ទីលំនៅអាត្មាវិញ ។

ព្រះមហាក្សត្រទ្រង់រកសេចក្ដីពិត បានឃើញជាក់ស្ដែងដូច្នេះហៅសុគតិគមនំ ត្រូវតាមគន្លងធម៌ហោង ។

ហើយក្រាបថ្វាយបង្គំលាត្រលប់ទៅកាន់លំនៅអាត្មាវិញហោង ។